**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**
លេខ : ០២២.....អ.ជ.ប.ជ.អ.

ភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៦

ទទួល ថ្ងៃទី: 21.01.2016 វេលា: 15h.50

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** របាយការណ៍ស្តីពីស្ថានភាពនៃថវិកាមូលនិធិសកល សម្រាប់ឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៧។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពរាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ តាមគំរូហិរញ្ញប្បទានថ្មី (New Funding Model) មូលនិធិសកលបានអនុម័តយល់ព្រមផ្តល់ជំនួយដូចខាងក្រោម៖

| ល.រ | ឈ្មោះកម្មវិធី | ចំនួនទឹកប្រាក់ | រយៈពេលអនុវត្ត |
|---|---|---|---|
| 1 | កម្មវិធីជម្ងឺរបេង | $ 15,664,272 | 1/1/2014-31/12/2017 |
| 2 | កម្មវិធីជម្ងឺគ្រុនចាញ់ | $ 29,100,897 | 1/07/2015-31/12/2017 |
| 3 | កម្មវិធីជម្ងឺអេដស៍ | $ 36,130,185 | 1/10/2015-31/12/2017 |
| 4 | កម្មវិធីពង្រឹងប្រព័ន្ធសុខាភិបាល(HSS) | $ 12,581,260 | 1/10/2015-31/12/2017 |
| | **សរុប** | $ **93,476,614** | |

មុននឹងផ្តល់ជំនួយនេះ មូលនិធិតម្រូវឲ្យរាជរដ្ឋាភិបាលចាប់ផ្តើមទទួលបន្ទុកចំណាយខាងផ្នែកធនធានមនុស្សជាបណ្តើរៗក្នុងនោះមានប្រាក់ឧបត្ថម្ភ(incentives)ដល់មន្ត្រីរាជការ និងប្រាក់បៀវត្សរ៍មន្ត្រីជាប់កិច្ចសន្យា ដើម្បីឲ្យមូលនិធិសកលបានរួចពីបន្ទុកនេះទាំងស្រុងចាប់ពីឆ្នាំ២០១៨តទៅ ។ ដោយមានការគាំទ្រពី **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ព្រមទាំងទទួលការឯកភាពពី **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងសុខាភិបាល ខ្ញុំបាទបានលើកសំណើជូនមូលនិធិសកលដូចខាងក្រោម៖

១/ រាជរដ្ឋាភិបាលសុខចិត្តឲ្យមូលនិធិសកលកាត់ប្រាក់ឧបត្ថម្ភ៥០% នៅឆ្នាំ២០១៦ និង ៥០% នៅឆ្នាំ២០១៧។

២/ សូមឲ្យមូលនិធិសកលរក្សាបន្ទុកប្រាក់បៀវត្សរ៍មន្ត្រីជាប់កិច្ចសន្យា១០០% នៅឆ្នាំ២០១៦ រាជរដ្ឋាភិបាលនឹងរំលែកបន្ទុក៥០% នៅឆ្នាំ២០១៧។

ដោយប្រកាន់ជំហរទន់ភ្លន់បែបនេះ មូលនិធិសកលក៏បានយល់ព្រមតាមសំណើរបស់យើង ហើយកិច្ចព្រមព្រៀងហិរញ្ញប្បទានលើកម្មវិធីទាំង៤ខាងលើ ក៏ត្រូវបានចុះហត្ថលេខាជាបន្តបន្ទាប់ដូចតទៅ៖

- កម្មវិធីជម្ងឺរបេង នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤
- កម្មវិធីជម្ងឺគ្រុនចាញ់ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥
- កម្មវិធីជម្ងឺអេដស៍ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥
- កម្មវិធីពង្រឹងប្រព័ន្ធសុខាភិបាល នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៥

ដើម្បីរៀបចំកញ្ចប់ថវិកាមន្ត្រីជាប់កិច្ចសន្យានេះ នៅក្នុងថវិកាកម្មវិធី ក្រសួងសុខាភិបាលឆ្នាំ២០១៧ និងដោយបានទទួលការណែនាំពីឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខ្ញុំបាទបានផ្តល់អនុសាសន៍ជូនក្រសួងសុខាភិបាល ឲ្យដឹកនាំក្រុមការងារបច្ចេកទេសដែលមានតំណាងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈចូលរួម។ គម្រោងថវិកាមន្ត្រីជាប់កិច្ចសន្យានេះនឹងត្រូវឲ្យចប់សព្វគ្រប់មុនថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦។ ការងារនេះអាចរាប់បានថាជាបដិភាគមួយរបស់រាជរដ្ឋាភិបាលដើម្បីទាក់ទាញឲ្យមូលនិធិសកលបន្តផ្តល់ជំនួយឥតសំណងមកកម្ពុជាយើងទៀតនៅក្រោយឆ្នាំ២០១៨។

ជាមួយគ្នានេះ ខ្ញុំបាទសូមជម្រាប **សម្តេចតេជោ** មេត្តាជ្រាបថា អាណត្តិខ្ញុំបាទជាប្រធានគណៈកម្មធិការសម្របសម្រួលនៃមូលនិធិសកលប្រចាំប្រទេសកម្ពុជា (CCC)(ឆ្នាំ២០១៤-២០១៥)បានចប់នៅដំណាច់ឆ្នាំ២០១៥។ ដោយពុំមានបេក្ខជនប្រជែង គណៈកម្មាធិការនេះ បានបោះឆ្នោតជាសម្ងាត់បន្តអាណត្តិថ្មីដល់ខ្ញុំបាទសម្រាប់ពីរឆ្នាំទៀត(២០១៦-២០១៧)ដោយសម្លេងគាំទ្រ២០លើ២០សម្លេង។

សេចក្តីដូចបានជម្រាបជូន សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជាសេចក្តីរាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

26.1.16

**អៀង_មូលី**

*ចម្លងជូន:*

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ